# សេចក្តីថ្លែងការណ៍
# ទម្លាក់បទចោទលើអតីតអ្នកយកព័ត៌មានកាសែត ឌឹ ខេមបូឌា ដេលី

ថ្ងៃព្រហស្បតិ៍ ទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២១

យើងដែលជាអ្នកសារព័ត៌មាន និង អង្គការ-សមាគមអ្នកសារព័ត៌មានចំនួន៣ ដែលបានចុះហត្ថលេខាខាងក្រោម សូមអំពាវនាវឱ្យតុលាការពន្លឿនដំណើរការក្តីករណីអតីតអ្នកកាសែត ឌឹ ខេមបូឌា ដេលី លោក អួន ភាព និង លោក Zsombor Peter។ យើងសូមអំពាវនាវដល់ព្រះរាជអាជ្ញា ឱ្យបង្ហាញភស្តុតាងដែលអាចបញ្ជាក់ថា អ្នកកាសែតទាំងពីរនាក់មានពិរុទ្ធក្នុងបទចោទ «ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍» ឬ បើមិនដូច្នេះទេ សូមទម្លាក់ចោលពាក្យប្តឹងឧទ្ធរណ៍ដែលស្នើឱ្យបន្តរឿងក្តីនេះ។

ករណីនេះបានអូសបន្លាយពេលជាយូរណាស់មកហើយ ដែលបានបង្កផលប៉ះពាល់ដល់ការងារ និងការរស់នៅរបស់អ្នកកាសែតទាំងពីរនាក់។ ចាប់តាំងពីពេលមានពាក្យបណ្តឹងមកលើពួកគាត់កាលពីជាងបីឆ្នាំមុន ពុំមានភស្តុតាងបញ្ជាក់ថាពួកគាត់ទាំងពីរនាក់មានកំហុស ឬ ពិរុទ្ធនោះឡើយ។ យើងជឿជាក់ថា អតីតអ្នកយកព័ត៌មានរបស់កាសែត ឌឹ ខេមបូឌា ដេលី លោក អួន ភាព និងលោក Zsombor Peter ដែលជាអតីតនិពន្ធនាយករងនៃកាសែតនេះគឺជាគោលដៅនៃយុទ្ធនាការនៃការឃាយី និង ការបំភិតបំភ័យតាមផ្លូវតុលាការដែលមិនមានការបង្ហាញភស្តុតាងផ្លូវច្បាប់ត្រឹមត្រូវ។

ដូចដែលបានចែងក្នុងច្បាប់របស់កម្ពុជានិងច្បាប់អន្តរជាតិ អ្នកសារព័ត៌មានទាំងឡាយគឺគ្មានទោស រហូតទាល់តែត្រូវបានរកឃើញ និងបង្ហាញភស្តុតាងយ៉ាងច្បាស់ថាមានពិរុទ្ធ ហើយអស់រយៈពេលជាង៣ឆ្នាំហើយ តុលាការបរាជ័យក្នុងបង្ហាញភស្តុតាងបញ្ជាក់អំពីពិរុទ្ធភាពរបស់ពួកគាត់ទាំងពីរនាក់។ កាលពីខែវិច្ឆិកា សាលាដំបូងខេត្តរតនគិរីបាន[ទម្លាក់ចោលការចោទប្រកាន់]លើពួកគាត់ ខណៈដើមបណ្តឹងបានដកពាក្យបណ្តឹងរបស់គាត់វិញ។ ហេតុអ្វីបានជា[ព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍]ចំពោះសេចក្តីសម្រេចរបស់តុលាការ?

អ្នកកាសែតទាំងពីរបានរងការធ្វើទុក្ខបុកម្នេញចំពោះការងារចុះរាយការណ៍ព័ត៌មាននៅឆ្នាំ២០១៧ ដើម្បីសម្ភាសពលរដ្ឋអំពីការបោះឆ្នោតកាលឆ្នាំនោះ។ វាគឺជាការវាយប្រហារទៅលើអ្នកកាសែតដែលបានឈ្នះពានរង្វាន់ទាំងពីរនាក់ និងទៅលើវិជ្ជាជីវៈរបស់យើងជាអ្នកសារព័ត៌មាន ក៏ដូចជាសេរីភាពសារព័ត៌មាននៅកម្ពុជា ក្រោមការអះអាងថាជាការអនុវត្តច្បាប់។

ក្នុងនាមជាមិត្តរួមអាជីពរបស់លោក អូន ភាព និងលោក Zsombor Peter យើងមិនអាចនៅស្ងៀមបានទេ។ ពួកយើងនឹងនៅជាមួយពួកគាត់ទាំងពីរដោយសាមគ្គីភាព និងប្រើសំឡេងរបស់យើងដើម្បីបញ្ជាក់ឱ្យច្បាស់ៗថា៖ ត្រូវតែទម្លាក់ចោលករណីនេះ។ កុំរំលោភសិទ្ធិរបស់យើងក្នុងការរាយការណ៍ព័ត៌មានដោយគ្មានការភ័យខ្លាច ឬ ភាព-លម្អៀង។ យើងរួមគ្នាដើម្បីគាំទ្រសេរីភាពសារព័ត៌មាន ហើយយើងសង្ឃឹមថាអ្នកសារព័ត៌មានដទៃទៀតទាំងអស់ រួមទាំងវិស័យឯកជននិងសាធារណៈនឹងចូលរួមជាមួយយើងនៅក្នុងកិច្ចការការពារនេះ។

អង្គការ-សមាគមដែលបានចុះហត្ថលេខា

១. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

២. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)

៣. ក្លឹបអ្នកសារព័ត៌មានបរទេសនៃកម្ពុជា (OPCC)